## អង្គការអុកស្វាមប្រចាំនៅកម្ពុជា

The Point ជាន់ទី៣ មហាវិថីម៉ៅសេទុង សង្កាត់ទួលស្វាយព្រៃ១
ខ័ណ្ឌបឹងកេងកង រាជធានីភ្នំពេញ

(+855) 23 885 412

(+855) 23 855 413

Info.Cambodia@oxfam.org

@OxfaminCambodia

@OxfamKH

WWW.CAMBODIA.OXFAM.ORG



ផ្តល់មូលនិធិដោយ

KOICA

អង្គការដៃគូ

OXFAM




© HURREDO

# លើកកម្ពស់ទឹកស្អាត និងអនាម័យ ប្រកបដោយ បរិយាបន្ន និងនិរន្តរភាព នៅតំបន់បឹងទន្លេសាប

ខែមិថុនា ឆ្នាំ២០២៤ - ខែធ្នូ ឆ្នាំ២០២៦

## បរិបទ

គម្រោង "លើកកម្ពស់ទឹកស្អាត និងអនាម័យប្រកបដោយបរិយាបន្ន និងនិរន្តរភាពនៅតំបន់បឹងទន្លេសាប" នឹងដោះស្រាយបញ្ហាសំខាន់ៗទាក់ទងនឹងទឹក និងអនាម័យ នៅតំបន់ជនបទនៃប្រទេសកម្ពុជា។ យោងតាមអង្គការសុខភាពពិភពលោកបានបង្ហាញថា ការអនុវត្តអនាម័យមិនមានសុវត្ថិភាពបានរួមចំណែកយ៉ាងសំខាន់ឲ្យមានជំងឺរាករូសខ្ពស់ក្នុងប្រទេសកម្ពុជា ដែលប្រមាណ ៦៩% នៃជំងឺរាករូសបណ្តាលមកពីការទទួលបានទឹក និងអនាម័យដែលមិនមានសុវត្ថិភាព។ ក្នុងឆ្នាំ ២០១៩ ៣៤% នៃគ្រួសារនៅតាមជនបទនៃប្រទេសកម្ពុជាខ្វះលទ្ធភាពទទួលបានទឹកសុវត្ថិភាព ដែលបង្កគ្រោះថ្នាក់ដល់សុខភាពមនុស្សប្រមាណ ២ លាននាក់។ លើសពីនេះ អង្គការសុខភាពពិភពលោកបានកំណត់ថា ប្រទេសកម្ពុជាមានអត្រាមរណភាពដោយសារជំងឺរាករូសខ្ពស់បំផុតនៅអាស៊ីអាគ្នេយ៍ ដែលមានអ្នកស្លាប់ចំនួន ៨,១០០ នាក់ក្នុងមួយឆ្នាំ។ បច្ចុប្បន្ននេះ មានតែប្រជាជនប្រមាណ ២៨% ប៉ុណ្ណោះ ដែលមានលទ្ធភាពទទួលបានអនាម័យជាមូលដ្ឋាន ហើយមានត្រឹមតែប្រជាជនប្រមាណ ៧% ប៉ុណ្ណោះ ដែលទទួលបានសេវាអនាម័យប្រកបដោយសុវត្ថិភាព ដោយបញ្ជាក់ពីតម្រូវការចាំបាច់សម្រាប់ធ្វើឲ្យប្រសើរឡើងផ្នែកទឹកស្អាត និងអនាម័យ។

WHO

អត្រាមរណភាព ដោយសារជំងឺរាករូស
**៨,១០០ នាក់** ក្នុងមួយឆ្នាំ

លទ្ធភាពទទួលបានអនាម័យជាមូលដ្ឋាន
**២៨%**

សេវាអនាម័យប្រកបដោយសុវត្ថិភាព
**៧%**

## វិធីសាស្ត្រ

កែលម្អលទ្ធភាពទទួលបានទឹកស្អាតប្រកបដោយនិរន្តរភាពក្នុងតំបន់ដែលពិបាក និងងាយរងគ្រោះ សម្រាប់សហគមន៍ដែលរងផលប៉ះពាល់ដោយការប្រែប្រួលអាកាសធាតុនៅក្នុងបបនីយជីវមណ្ឌលបឹងទន្លេសាប។

បង្កើនការយល់ដឹង និងការអនុវត្តក៏ដូចជាការធ្វើឱ្យប្រសើរឡើងនូវលទ្ធភាពទទួលបានទឹកស្អាត និងអនាម័យដល់ក្រុមគោលដៅក្នុងសហគមន៍ដែលរងផលប៉ះពាល់ដោយការប្រែប្រួលអាកាសធាតុនៅក្នុងបបនីយជីវមណ្ឌលបឹងទន្លេសាប។

គម្រោងនេះនឹងត្រូវអនុវត្តនៅឃុំចំនួន១៤ នៅទូទាំងស្រុកចំនួន១០ ក្នុងខេត្តសៀមរាប និងខេត្តបាត់ដំបង។ គម្រោងត្រូវបានបង្កើតឡើងដើម្បីជួយដល់ប្រជាជនប្រមាណ ១០៦,៤៥៥ នាក់ (៥០% ជាស្ត្រី និងកុមារី)។ គម្រោងនឹងផ្តល់អាទិភាពដល់ក្រុមងាយរងគ្រោះ រួមទាំងស្ត្រី និងជនពិការ។ អង្គការអុកស្វាម នឹងលើកកម្ពស់សមត្ថភាពរបស់អ្នកពាក់ព័ន្ធក្នុងស្រុក ដើម្បីធានាឲ្យមានសមភាពយេនឌ័រ និងបរិយាបន្នដោយជួយសម្របសម្រួលឲ្យមានកម្មវិធីផ្សេងៗដែលមានភាគីពាក់ព័ន្ធជាច្រើនចូលរួមក្នុងការគាំទ្រមតិ និងការចែករំលែកព័ត៌មានជាដើម។



យើងនឹងសាងសង់ស្ថានីយ៍ផលិតទឹកស្អាត ផ្តល់ការអប់រំអនាម័យ និងរៀបចំកម្មវិធីផ្លាស់ប្តូរឥរិយាបថដើម្បីលើកកម្ពស់ការអនុវត្តអនាម័យត្រឹមត្រូវ។

## សូចនាករសំខាន់ៗ

*គម្រោងនឹងតាមដានវឌ្ឍនភាពតាមរយៈសូចនាករជាច្រើន៖*

### សមិទ្ធផលទី ១

នៅឆ្នាំ ២០២៦ គម្រោងមានគោលបំណងផ្តល់ឱ្យអ្នកទទួលផលដោយផ្ទាល់ដល់ ៦,៦០០ គ្រួសារដែលមានលទ្ធភាពទទួលបានទឹកប្រកបដោយសុវត្ថិភាព និងបង្កើតគណៈកម្មការគ្រប់គ្រងទឹកចំនួន ១១ នាក់សម្រាប់ការគ្រប់គ្រងសហគមន៍។



### សមិទ្ធផលទី ២

បង្កើនចំនួនគ្រួសារប្រើប្រាស់បង្គន់អនាម័យដោយផ្ទាល់ដែលបានកែលម្អ និងបង្កើនភាគរយនៃអ្នកភូមិដែលអនុវត្តការលាងសម្អាតដៃនៅពេលចាំបាច់ចំនួន ១,៣០០ គ្រួសារ។



## ដៃគូ

### ផ្តល់មូនិធិដោយ

ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិកូរ៉េ (KOICA)

### អង្គការដៃគូ

អង្គការអភិវឌ្ឍន៍ធនធានមនុស្ស និងសេដ្ឋកិច្ចជនបទ

### ដៃគូយុទ្ធសាស្ត្រ

- ក្រសួងអភិវឌ្ឍន៍ជនបទ
- មន្ទីរអភិវឌ្ឍន៍ជនបទ
- មន្ទីរអប់រំ យុវជន និងកីឡា
- រដ្ឋបាលថ្នាក់ខេត្ត និងស្រុក នៃក្រសួងមហាផ្ទៃ
- អាជ្ញាធរមូលដ្ឋាន
- សាលាបឋមសិក្សា